# អនុសាសន៍សម្រាប់ការអភិវឌ្ឍវិស័យសិល្បៈ និងវប្បធម៌ ពីវិស័យទេសចរណ៍

## ដោយអ្នកទទួលអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌

## នៃសមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកែច្នៃនៃកម្ពុជា

__អនុសាសន៍ចំនួន ៦ មានដូចខាងក្រោម៖__

*១)* ***__បញ្ចូលតារាងព័ត៌មានអំពីសិល្បៈ វប្បធម៌នៅតាមស្តង់ទេសចរណ៍នានា៖__*** តាមការស្រាវជ្រាវរបស់អ្នកទទួលអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ ពួកគេរកឃើញថា នៅតាមស្តង់ព័ត៌មានទេសចរណ៍ភាគច្រើនមិនមានព័ត៌មានអំពីសិល្បៈ និងវប្បធម៌នោះទេ។ កង្វះខាតព័ត៌មាននេះបង្កការលំបាកដល់ទេសចរដែលចង់បានព័ត៌មាន ដើម្បីចូលរួមទស្សនា គាំទ្រ និងឈ្វេងយល់អំពីវប្បធម៌កម្ពុជា។ ការផ្តួចផ្តើមឱ្យមានព័ត៌មានសិល្បៈនៅតាមស្តង់ព័ត៌មានទេសចរណ៍នីមួយៗ មិនត្រឹមផ្តល់ព័ត៌មានបន្ថែមដល់ទេសចរប៉ុណ្ណោះទេ តែថែមទាំងជួយពង្រីកទីផ្សារជូនសិល្បករ និងប្រតិបត្តិករវប្បធម៌ថែមទៀតផង។

*២)* ***__កំណត់មន្ត្រីម្នាក់សម្រាប់ទំនាក់ទំនងរវាងវិស័យសិល្បៈ និងវប្បធម៌៖__*** ជារឿយៗ សិល្បករឯករាជ្យមានការពិបាកស្វែងរកទំនាក់ទំនង និងព័ត៌មាននានាពីវិស័យទេសចរណ៍ ដើម្បីទទួលបានឱកាស (សម្តែង និងហិរញ្ញវត្ថុ) និងបានចូលរួមប្រកួតប្រជែងបញ្ចេញថ្វៃដី ដល់ភ្ញៀវជាតិ និងអន្តរជាតិ។ ដូចនេះ ប្រសិនបើមានទំនាក់ទំនងដោយជិតស្និទ្ធពីមន្ត្រីនៃក្រសួងទេសចរណ៍ទទួលភារៈទំនាក់ទំនងជាមួយសិល្បករ ឬសមាគមឯករាជ្យ នោះទំនាក់ទំនងនេះនឹងជួយផ្តល់លទ្ធភាពដល់ក្រសួងទេសចរណ៍នូវសេវាកម្មថ្មីៗ ទំនាក់ទំនងមានប្រសិទ្ធិភាព និងឆាប់រហ័ស។

*៣)* ***__ស្នើឱ្យមានរៀបចំព្រឹត្តិការណ៍សិល្បៈមួយក្រោមប្រធានបទ «បញ្ចពណ៌ភ្នំពេញ»៖__*** ព្រឹត្តិការណ៍សិល្បៈបញ្ចពណ៌ភ្នំពេញជាកម្មវិធី (អាចជាប្រចាំខែ ឬប្រចាំត្រីមាស) សម្រាប់បង្ហាញពីទម្រង់សិល្បៈចម្រុះ ដើម្បី៖ ***១)*** ទាក់ទាញទេសចរឱ្យមកទស្សនាកម្ពុជា និង ***២)*** ផ្តល់ឱកាសការងារដល់សិល្បករ និងប្រតិបត្តិករវប្បធម៌បានបញ្ចេញស្នាដៃជាប្រចាំ។ កម្មវិធីនេះត្រូវបានលើកឡើងដោយស្របនឹងដំណឹងអំពីការវិវត្តតំបន់ថ្មើរជើងតាមមាត់ទន្លេ។ ប្រសិនបើព្រឹត្តិការណ៍សិល្បៈបញ្ចពណ៌ អាចកើតឡើងមែននោះ នៅភ្នំពេញអាចក្លាយជាទីក្រុងដែលមានសិល្បៈវប្បធម៌រស់រវើកជាប្រចាំ ដែលផ្តល់ឱកាសដល់ទេសចរឱ្យបានកម្សាន្តនៅកម្ពុជាបានយូរ។ នៅប្រទេសថៃ មានកម្មវិធីមួយដែលមានឈ្មោះថា Colorful Bangkok ដែលអ្នកទទួលអាហារូបករណ៍យល់ឃើញថា ជាកម្មវិធីមួយដ៏ល្អ និងមានផលប្រយោជន៍ជាច្រើនលើសលប់ សម្រាប់ទេសចរ (ក្នុងស្រុក និងអន្តរជាតិ) និងសិល្បករផងដែរ។

*៤)* ***__ផ្តល់ទីតាំងសម្តែង៖__*** ជារឿយៗ សិល្បករឯករាជ្យ ជាពិសេសក្រុមសិល្បករសហសម័យ ក៏ដូចជាក្រុមសិល្បៈប្រពៃណីផងដែរ តែងមានការលំបាកដោយខ្វះខាតទីតាំងសម្រាប់សម្តែងជាទៀងទាត់។ ជាញឹកញាប់ ទេសចរអន្តរជាតិតែងទូរស័ព្ទមកអង្គការសិល្បៈខ្មែរអមតៈ (ដែលធ្លាប់មានឆាកសម្តែងកាលពេលមុនកូវីដ១៩ តែឥឡូវត្រូវបិទ) អំពីកម្មវិធីសម្តែងដែលពួកគេអាចមកទស្សនា។ គួរឱ្យសោកស្តាយដែលនៅភ្នំពេញមិនមានទីតាំងណាមួយ ដែលអាចផ្តល់ឱកាសដល់សិល្បករ ដើម្បីសម្តែងជូនទេសចរ ដើម្បីទទួលបានកម្រៃផង។

*៥)* ***<u>ស្នើបង្កើតជាកញ្ចប់ថវិកាសម្រាប់ទ្រទ្រង់ដល់ស្នាដៃសិល្បៈដែលមានប្រយោជន៍ដល់វិស័យទេសចរណ៍</u>*** *៖* ការមានកញ្ចប់ថវិកាសម្រាប់សិល្បករដែលចូលរួមសម្តែងក្នុងឱកាសណាមួយ ជាការចាំបាច់បំផុត ដើម្បីផ្គត់ផ្គង់ជីវភាព ផ្តល់តម្លៃការងារដល់សិល្បករ។ តាមការសង្កេតរបស់អ្នកទទួលអាហារូបករណ៍ តម្លៃឈ្នួលការងារត្រូវបានគេគិតតែលើការសម្តែងប៉ុណ្ណោះ ដោយភាគច្រើន គេមិនបានគិតគូរដល់ថ្លៃហាត់សម ថ្លៃធ្វើដំណើរ ថ្លៃច្នៃសម្លៀកបំពាក់ឡើយ។ ការគិតគូរទូលំទូលាយទាំងនេះជួយធ្វើឱ្យកម្រិតជីវភាពរបស់សិល្បៈកាន់តែប្រសើរឡើង។

*៦)* ***<u>បង្កើតមូលនិធិគ្រាប់ពូជ (Seed Funding) សម្រាប់បណ្តុះបណ្តាសហគ្រិនភាពវប្បធម៌៖</u>*** សំណើនេះជាសំណើសម្រាប់សហប្រតិបត្តិការរវាងក្រសួងនានា។ បន្ទាប់ពីសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនខែ ក្រុមអ្នកទទួលអាហារូបករណ៍បានយល់ថា ការមានកញ្ចប់ថវិការួមគ្នារវាងក្រសួងពាក់ព័ន្ធនានា រួមមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ផងដែរ ក្នុងការបង្កើតកម្មវិធីសិក្សាអប់រំអំពីសហគ្រិនភាពវប្បធម៌ដល់យុវជនពីថ្នាក់វិទ្យាល័យ។ កម្មវិធីសិក្សានេះនឹងជួយឱ្យយុវជនទាំងនោះនឹងក្លាយជាអ្នកដឹកនាំវប្បធម៌ ដែលជាទុនចូលរួមចំណែកអភិវឌ្ឍវប្បធម៌ និងទេសចរណ៍ បើទោះជាដោយប្រយោលក្តី។

***<u>សារតា</u>***

នាសៀលថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងទេសចរណ៍ ក្រុមការងារ អ្នកប្រឹក្សា ក្រុមអ្នកទទួឡអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ មានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ដោយបានចូលជួបសម្តែងការគួរសមថ្នាក់ដឹកនាំរបស់ក្រសួងទេសចរណ៍ ជាមួយ ឯកឧត្តម តុប សុភ័ក រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមរដ្ឋមន្ត្រី អម ដោយ លោក សៀង នាគ អគ្គនាយករង តំណាង ឯកឧត្តម ថោង រដ្ឋសក្តិ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ រួចជាមួយមន្ត្រីជំនាញជាច្រើននាក់ ក្នុងគោលបំណងដើម្បីសម្តែងការគួរសម ពិភាក្សាការងារជំរុញកិច្ចសហប្រតិបត្តិការវិស័យ ទេសចរណ៍ និងពង្រឹងកិច្ចសហការក្នុងការផ្សព្វផ្សាយវិស័យទេសចរណ៍ សិល្បៈ និងវប្បធម៌។

ក្នុងជំនួបប្រជុំនេះ អ្នកទទួលអាហារូបករណ៍ ដែលសុទ្ធសឹងតែជាសិល្បករ ផលិតករ ប្រតិបត្តិករវប្បធម៌ មកពីជំនាញសិល្បៈផ្សេងៗគ្នា និងមានបទពិសោធន៍ជាច្រើនឆ្នាំ បានសិក្សា ស្រាវជ្រាវ និងឈ្វេងយល់អំពីភាពអាចធ្វើបានរវាងវិស័យសិល្បៈវប្បធម៌ និងវិស័យទេសចរណ៍។ ពួកគេបានកត់សម្គាល់នូវកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងការដឹកនាំផ្ទាល់របស់ឯកឧត្តមក្នុងការអភិវឌ្ឍវិសាលភាព និងសក្តានុពលនៃវិស័យវប្បធម៌បានរីកចម្រើនគួរជាទីមោទនៈ។ ទន្ទឹមគ្នានេះ អ្នកទទួលអាហារូបករណ៍ក៏បានលើកឡើងអំពីតួនាទីដ៏សកម្ម និងធំធេងនៃវិស័យសិល្បៈ វប្បធម៌ ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យទេសចរណ៍។ ដោយយល់ឃើញថា ការជួយឧបត្ថម្ភ គាំទ្រ និងវិនិយោគពីវិស័យទេសចរណ៍ ដល់វិស័យសិល្បៈ និងវប្បធម៌ រឹតតែទាញបានប្រយោជន៍ដ៏ច្រើន។